# សេចក្តីប្រកាសអំពីកម្មវិធីបន្តការសិក្សានៅរដូវក្តៅ
## ខែឧសភា ២០១៦

ជូនចំពោះ មាតាបិតា/អាណាព្យាបាល

ទោះជាចុងបញ្ចប់នៃឆ្នាំសិក្សានៅជាងមួយខែទៀតក៏ដោយ ក៏មិនមែនជាការប្រញាប់ពេកដែរក្នុងការចាប់ផ្តើមគិតអំពីផែនការនៅរដូវក្តៅសម្រាប់កូនលោកអ្នក។ នៅពេលដែលរដូវក្តៅជាពេល សប្បាយរីករា និង លំហែកាយ ចំពោះសិស្សដែលត្រៀមចូលរៀននៅវិទ្យាល័យ គឺជាពេលដើម្បីត្រៀមខ្លួនសម្រាប់ដំណាក់កាលថ្មីមួយនៃការអប់រំ!

នៅរដូវក្តៅនេះ នឹងមាន កម្មវិធីបន្តការសិក្សានៅរដូវក្តៅ នៅវិទ្យាល័យទូទាំងក្រសួង។ សិស្សានុសិស្សដែលនឹងចូលរៀនថ្នាក់ទី៩ នៅខែកញ្ញា ២០១៦ ដែលនឹងទៅរៀននៅសាលាមួយ ក្នុងចំណោមសាលាខាងក្រោមនេះ មានសិទ្ធិចូលរួមក្នុងកម្មវិធីនេះ។ សេចក្តីលម្អិតអំពីកម្មវិធីបន្តការសិក្សានៅរដូវក្តៅ មានដូចតទៅ៖

- **ថ្ងៃខែនៃកម្មវិធី៖** ថ្ងៃទី៥ ខែកក្កដា ដល់ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៦ (ថ្ងៃច័ន្ទ ដល់ ថ្ងៃសុក្រ)
- **រយៈពេលសិក្សាក្នុងមួយថ្ងៃៗ៖** ម៉ោង ៨:៣០ ព្រឹក ដល់ ម៉ោង ១:00 រសៀល
- **តម្លៃនៃកម្មវិធី៖ ឥតគិតថ្លៃ** (នឹងផ្តល់ អាហារពេលព្រឹក អាហារថ្ងៃត្រង់ និង យានជំនិះ)

**<u>វិទ្យាល័យដែលចូលរួមក្នុងកម្មវិធីបន្តការសិក្សានៅរដូវក្តៅ</u>**

| | | | |
|---|---|---|---|
| Abraham Lincoln | John Bartram | Northeast | School of the Future |
| Benjamin Franklin | Kensington Health Sciences | Overbrook | South Philadelphia |
| Frankford | Kensington CAPA | Penn Treaty | Strawberry Mansion |
| George Washington | Kensington Urban Education & Business | Roxborough | Thomas Edison |
| Horace Furness | Martin Luther King | Samuel Fels | West Philadelphia |
| | | | William A. Sayre |

ការរៀបចំ និង កម្មវិធីសិក្សា សម្រាប់កម្មវិធីបន្តការសិក្សានៅរដូវក្តៅ នឹងផ្តោតទៅលើការសិក្សា ការត្រៀមខ្លួនសម្រាប់មហាវិទ្យាល័យ និង អាជីព។ នេះរួមមានទាំងបទពិសោធន៍នៅ ក្នុង និង ក្រៅ ថ្នាក់រៀន ដែលអាចជួយដល់ការផ្លាស់ប្តូររបស់កូនលោកអ្នកទៅកាន់ការសិក្សាដ៏លំបាកនៅវិទ្យាល័យ។

ដើម្បីចុះឈ្មោះសម្រាប់ កម្មវិធីបន្តការសិក្សានៅរដូវក្តៅ សូមបំពេញលិខិតដែលបានភ្ជាប់មកជាមួយនេះ ហើយប្រគល់ឲ្យទៅលេខាធិការ ដើម្បីចុះឈ្មោះចូលរៀន។ កន្លែងមានកំណត់ ដោយមូលហេតុនេះ សូមឆ្លើយតបឲ្យបានឆាប់រហ័ស។

បើមានសំណួរអំពី កម្មវិធីបន្តការសិក្សានៅរដូវក្តៅ ត្រូវសាកសួរតាមអ៊ីមែល summerprograms2016@philasd.org។

ដោយសេចក្តីរាក់ទាក់

នាយកសាលា

**ការឆ្លើយតបរបស់មាតាបិតា**

**កម្មវិធីបន្តការសិក្សានៅរដូវក្ដៅ ឆ្នាំ២០១៦**

ឈ្មោះក្មេង/Child Name: ___________________

❑ កូនខ្ញុំ**នឹង**ចូលរួមក្នុងកម្មវិធីបន្តការសិក្សានៅរដូវក្ដៅ ឆ្នាំ២០១៦/My child WILL participate in the 2016 Summer Bridge Program

**វិទ្យាល័យដែលក្មេងនឹងចូលរៀននៅ (ខែកញ្ញា ២០១៦)/High School Attending (September 2016):**

________________________________________________

❑ កូនខ្ញុំ**នឹងមិន**ចូលរួមក្នុងកម្មវិធីបន្តការសិក្សានៅរដូវក្ដៅ ២០១៦ ទេ/My child WILL NOT participate in the 2016 Summer Bridge Program

___________________________________________________________ ________________________

ហត្ថលេខារបស់ មាតាបិតា/អាណាព្យាបាល/Parent/Guardian Signature ថ្ងៃខែ/Date

លេខទូរស័ព្ទរបស់ មាតាបិតា/អាណាព្យាបាល/Parent/Guardian Phone number: ________________________

**ព័ត៌មានសម្រាប់ទាក់ទងនៅពេលមានអាសន្ន៖**

ឈ្មោះ/Name: ____________________________________________

អាស័យដ្ឋាន/Address: _____________________________________

ទូរស័ព្ទ/Phone: __________________________________________